ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០២ សហវ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩

# សារាចរណែនាំបន្ថែម
## ស្តីពី
## កិច្ចបញ្ជិការជួទេយ្យបុរេប្រទាននៅតាមក្រសួង-ស្ថាប័ន និងមន្ទីរ-អង្គភាពនៅខេត្ត-រាជធានី

ដើម្បីអនុវត្តកិច្ចបញ្ជិការជួទេយ្យបុរេប្រទាននៅតាមក្រសួង-ស្ថាប័ន និង មន្ទីរ-អង្គភាពនៅខេត្ត-រាជធានី អោយបានស្របទៅតាមទិសដៅនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអោយមានការឯកភាពទូទាំងប្រទេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំនូវចំណុចមួយចំនួនបន្ថែមលើសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការចំណាយតាមនីតិវិធីរជួទេយ្យបុរេប្រទាន និងសារាចរណែនាំបន្ថែមលេខ ០០៣ សហវ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៧ ដូចខាងក្រោមៈ

ក-<u>នៅថ្នាក់ជាតិៈ</u>

-រជួទេយ្យករបុរេប្រទាន និងរជួទេយ្យករបុរេប្រទានរងនៅនាយកដ្ឋាន ឬ ការិយាល័យ ដែលទទួលបន្ទុកការងារគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួង-ស្ថាប័ន ដែលបានបង្កើតរជួទេយ្យបុរេប្រទាន និងបានតែងតាំងរជួទេយ្យករបុរេប្រទានរួច ត្រូវចុះកិច្ចបញ្ជិការជួទេយ្យបុរេប្រទាន ទៅតាមខ្លឹមសារនៃសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការចំណាយតាមនីតិវិធីរជួទេយ្យបុរេប្រទាន។

-ដោយឡែក ចំពោះអាគារ មន្ទីរពេទ្យ សាលារៀន ម្ចាស់គម្រោង ឬ អង្គភាពផ្សេងៗទៀត ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ហើយដែលពុំទាន់បានបង្កើតរជួទេយ្យបុរេប្រទាន និងតែងតាំងរជួទេយ្យករបុរេប្រទាន គឺគ្រាន់តែកាន់បញ្ជីបេឡា បង្កើតប័ណ្ណចំណូលយោងតាមប័ណ្ណចំណាយដែលរជួទេយ្យករបុរេប្រទានផ្តល់ជូន បង្កើតប័ណ្ណចំណាយដោយផ្អែកតាមគោលការណ៍ចំណាយ និងវិក័យប័ត្រ ដែលមានការឯកភាពពីប្រធានអង្គភាព និង ធ្វើរបាយការណ៍ចំណាយតាមជំពូក គណនី អនុគណនី ដែលបានចំណាយ ដោយបញ្ជាក់ពីលេខប័ណ្ណចំណាយ និងថ្ងៃ-ខែ-ឆ្នាំ ព្រមទាំងបរិយាយអោយបានច្បាស់លាស់ រួចផ្ញើជូនទៅរជួទេយ្យករបុរេប្រទានថ្នាក់លើ។ ចំពោះប័ណ្ណចំណាយត្រូវចុះហត្ថលេខាដោយប្រធានគណនេយ្យ និងប្រធានអង្គភាព ឬ ប្រធានគម្រោង ហើយត្រូវដាក់លេខរៀងទៅតាមអង្គភាពនីមួយៗ។

-រដ្ឋលេខាធិការបុរេប្រទាន ក្រោយពីបានទទួលសក្ខីប័ត្រ និងរបាយការណ៍ចំណាយរួច គឺពុំចាំបាច់កត់ត្រាលំអិតនៅក្នុងបញ្ជីបេឡា ឬ ទិន្នានុប្បវត្តិសៀវភៅធំទៀតទេ ព្រោះកិច្ចបញ្ជិកានេះបានអនុវត្តនៅពេលប្រគល់ថវិកាជូនទៅអាជ្ញាធរ អង្គភាព មន្ទីរពេទ្យ សាលារៀន និងម្ចាស់គម្រោងរួចហើយ គឺគ្រាន់តែកត់ត្រាឥណពន្ធ គណនីលេខ ៤៧.២ និងឥណទាន គណនីលេខ ៤៧.៣ នៅពេលដែលបានបញ្ជូនលិខិតយុត្តិការដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម។

-នាយកដ្ឋាន ឬ ការិយាល័យដែលទទួលបន្ទុកការងារគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវធ្វើការកាត់ស្តុកឥណទានរួម ហើយរដ្ឋលេខាធិការបុរេប្រទានត្រូវធ្វើការកាត់ស្តុកឥណទានរដ្ឋលេខាបុរេប្រទាន។

-នៅពេលបានទទួលដីកាអមបញ្ចេញអាណត្តិបើកប្រាក់ពីអគ្គនាយកដ្ឋានរតនាគារជាតិវិញ រដ្ឋលេខាធិការបុរេប្រទានត្រូវកត់ត្រាឥណពន្ធគណនីលេខ ៥៩ និងឥណទានគណនីលេខ ៤៧.២។

- នៅរាល់ដំណាច់ខែនីមួយៗ រដ្ឋលេខាធិការបុរេប្រទានត្រូវបង្កើតតារាងតុល្យភាពរដ្ឋលេខាបុរេប្រទានរួមប្រចាំខែ។

-ការទូទាត់ប្រាក់រដ្ឋលេខាបុរេប្រទាន ត្រូវភ្ជាប់មកជាមួយនូវៈ

+អាណត្តិនិយ័តកម្ម ចំនួន ០១ (មួយ) ច្បាប់

+ដីកាអមបញ្ចេញអាណត្តិបើកប្រាក់និយ័តកម្ម ចំនួន ០៣ (បី) ច្បាប់

+ដីកាអមលិខិតយុត្តិកា ចំនួន ០១ (មួយ) ច្បាប់ (រៀបរាប់លិខិតយុត្តិការភ្ជាប់តាម)

+សលាកប័ត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ ទៅតាមអនុគណនីនីមួយៗ ដែលមានលើអាណត្តិបើកប្រាក់និយ័តកម្មចំនួន ០១ (មួយ) ច្បាប់

+តារាងតុល្យភាពរដ្ឋលេខាបុរេប្រទានប្រចាំខែ ចំនួន ០១ (មួយ) ច្បាប់

+ប័ណ្ណចំណាយ ដែលចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ (ប័ណ្ណថតចំលង)ចំនួន ០១ (មួយ) ច្បាប់

+ប័ណ្ណចំណាយ ដែលចេញដោយរដ្ឋលេខាធិការបុរេប្រទានផ្តល់ជូនអង្គភាពបន្ត (អាជ្ញាធរ មន្ទីរពេទ្យ សាលារៀន ម្ចាស់គម្រោង ឬ អង្គភាពផ្សេងៗទៀត) (ប័ណ្ណថតចំលង) ចំនួន ០១ (មួយ) ច្បាប់

+ប័ណ្ណចំណាយជាក់ស្តែង ដោយមានភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយ និងវិក័យប័ត្រ

+របាយការណ៍ចំណាយមានបញ្ជាក់លេខប័ណ្ណចំណាយ ថ្ងៃ-ខែ-ឆ្នាំ និងបរិយាយទៅតាមអនុគណនី នីមួយៗ ចំនួន ០១ (មួយ) ច្បាប់

-មូលដ្ឋាននៃការផ្ទៀងផ្ទាត់តួលេខរវាងរដ្ឋលេខាធិការបុរេប្រទាន ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ គឺត្រូវពិនិត្យលើសមតុល្យៈ

+សម្រាប់ថវិកាមិនមែនកម្មវិធីគណនីលេខ ៥៤៣ នៅអគ្គនាយកដ្ឋានរតនាគារជាតិ ជាមួយគណនីលេខ ៥៩.០១ នៅសាមីក្រសួង-ស្ថាប័ន

+សម្រាប់ថវិកាតាមកម្មវិធីគណនីលេខ ៥៤៤ នៅអគ្គនាយកដ្ឋានរតនាគារជាតិ ជាមួយគណនីលេខ ៥៩.០២ នៅសាមីក្រសួង-ស្ថាប័ន។

ខ-<u>នៅថ្នាក់ក្រោមជាតិៈ</u>

-រដ្ឋទេយ្យករបុរេប្រទាន ដែលបំពេញការងារនៅតាមមន្ទីរជំនាញនីមួយៗ ត្រូវបង្កើតប័ណ្ណចំណាយទៅតាមថ្នាក់ដូចតទៅៈ

+ប័ណ្ណចំណាយសម្រាប់មន្ទីរជំនាញផ្ទាល់

+ប័ណ្ណចំណាយ ដែលផ្តល់ជូនការិយាល័យតាមស្រុក-ខណ្ឌ-ក្រុង ឬ អង្គភាពផ្សេងៗទៀតក្រោមឱវាទ

+ប័ណ្ណចំណាយ សម្រាប់ការិយាល័យស្រុក-ខណ្ឌ-ក្រុង និងអង្គភាពផ្សេងៗទៀតក្រោមឱវាទរបស់មន្ទីរជំនាញ

+ប័ណ្ណចំណាយ ដែលការិយាល័យស្រុក-ខណ្ឌ-ក្រុង ផ្តល់ជូនអង្គភាពជំនាញក្រោមឱវាទ ( សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព ។ល។ )

+ប័ណ្ណចំណាយ ដែលអង្គភាពជំនាញក្រោមឱវាទ ការិយាល័យស្រុក-ខណ្ឌ-ក្រុងចំណាយផ្ទាល់

-រដ្ឋទេយ្យករបុរេប្រទាន ត្រូវកាន់កិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទានទៅតាមមន្ទីរជំនាញខេត្ត-រាជធានីនីមួយៗ។ ដោយឡែក អង្គភាពផ្សេងៗទៀត ដែលស្ថិតក្រោមឱវាទរបស់មន្ទីរជំនាញខេត្ត-រាជធានី ដូចជាការិយាល័យស្រុក-ខណ្ឌ-ក្រុង ឬ អង្គភាពផ្សេងៗ (មន្ទីរពេទ្យ សាលារៀន ។ល។) ហើយនៅពុំទាន់បានបង្កើតរដ្ឋទេយ្យបុរេប្រទាន និងពុំទាន់បានតែងតាំងរដ្ឋទេយ្យករបុរេប្រទានទេនោះ គឺពុំចាំបាច់កាន់កិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទានទេ គឺគ្រាន់តែកាន់បញ្ជីបេឡា បង្កើតប័ណ្ណចំណូលយោងតាមប័ណ្ណចំណាយ ដែលរដ្ឋទេយ្យករបុរេប្រទានផ្តល់ជូន ហើយត្រូវបង្កើតប័ណ្ណចំណាយ ដោយផ្អែកទៅតាមគោលការណ៍ចំណាយ និងវិក័យប័ត្រ ដែលមានការឯកភាពពីប្រធានអង្គភាព។

-ការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុង ត្រូវបង្កើតប័ណ្ណចំណាយជូនអង្គភាពក្រោមឱវាទ ដែលនៅពុំទាន់បានបង្កើតរដ្ឋទេយ្យបុរេប្រទាន និងពុំទាន់បានតែងតាំងរដ្ឋទេយ្យករបុរេប្រទាន។ អង្គភាពក្រោមឱវាទ ការិយាល័យ ជំនាញស្រុក-ខណ្ឌ-ក្រុង (សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព។ល។) គឺគ្រាន់តែកាន់បញ្ជីបេឡា និងបង្កើតប័ណ្ណចំណូលយោងទៅតាមប័ណ្ណចំណាយដែលការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុងផ្តល់ជូន ដោយត្រូវបង្កើតប័ណ្ណចំណាយយោងទៅតាមគោលការណ៍ចំណាយ និងវិក័យប័ត្រ ដែលមានការឯកភាពពីប្រធានអង្គភាព និងត្រូវធ្វើរបាយការណ៍ចំណាយតាមជំពូក គណនី អនុគណនី ដែលបានចំណាយ ហើយត្រូវបញ្ជាក់ពីលេខប័ណ្ណចំណាយ ថ្ងៃ-ខែ-ឆ្នាំ ព្រមទាំងបរិយាយអោយបានច្បាស់លាស់ រួចផ្ញើជូនទៅការិយាល័យជំនាញ ស្រុក-ខណ្ឌ-ក្រុង។

-ការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុង ត្រូវធ្វើការបូកសរុបរបាយការណ៍ ដែលបានទទួលពីអង្គភាពក្រោមឱវាទ ជាមួយរបាយការណ៍ចំណាយរបស់ខ្លួនផ្ទាល់ រួចបញ្ជូនមកមន្ទីរជំនាញខេត្ត-រាជធានី ដោយភ្ជាប់ជាមួយនូវសក្ខីប័ត្រ ដែលបានចំណាយផ្ទាល់ (ប័ណ្ណចំណាយ គោលការណ៍ចំណាយ និងវិក័យប័ត្រ) ព្រមទាំងប័ណ្ណចំណូល-ចំណាយ របាយការណ៍ចំណាយ គោលការណ៍ចំណាយ និងវិក័យប័ត្ររបស់អង្គភាពក្រោមឱវាទ។

-រដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរងនៃមន្ទីរជំនាញខេត្ត-រាជធានី ក្រោយពីបានទទួលរបាយការណ៍ និងសក្ខីប័ត្ររបស់ការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុងហើយ គឺពុំចាំបាច់ធ្វើការកត់ត្រាក្នុងបញ្ជីបេឡា និងទិន្នានុប្បវត្តិសៀវភៅធំទៀតទេ ព្រោះកិច្ចបញ្ជិកាត្រូវបានអនុវត្តនៅពេលប្រគល់ថវិកាជូនទៅការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុងរួចហើយត្រូវធ្វើការកត់ត្រាឥណពន្ធគណនីលេខ ៤៧.២ និងឥណទានគណនីលេខ ៤៧.៣ នៅពេលដែលបញ្ជូនលិខិតយុត្តិកាដើម្បីបោះផ្សាយអាណត្តិបើកប្រាក់និយ័តកម្ម។ មន្ទីរជំនាញខេត្ត-រាជធានី ត្រូវធ្វើការកាត់ស្តុកឥណទានរួម ហើយរដ្ឋទេយ្យករបុរេប្រទាន ត្រូវកាត់ស្តុកឥណទានរដ្ឋទេយ្យបុរេប្រទាន។ រដ្ឋទេយ្យករបុរេប្រទាន កត់ត្រាឥណពន្ធគណនីលេខ ៥៩ និងឥណទានគណនីលេខ ៤៧.២ នៅពេលដែលទទួលបានដីកាអមបញ្ចេញអាណត្តិបើកប្រាក់ពីរតនាគារខេត្ត-រាជធានីវិញ។ នៅដំណាច់ខែនីមួយៗ រដ្ឋទេយ្យករបុរេប្រទានត្រូវបង្កើតតារាងតុល្យភាពរដ្ឋទេយ្យបុរេប្រទានប្រចាំខែ។

-ការទូទាត់រដ្ឋទេយ្យបុរេប្រទានត្រូវភ្ជាប់មកជាមួយនូវៈ

+អាណត្តិបើកប្រាក់និយ័តកម្ម ចំនួន ០១ (មួយ) ច្បាប់

+ដីកាអមបញ្ចេញអាណត្តិបើកប្រាក់ ចំនួន ០៣ (បី) ច្បាប់

+ដីកាអមលិខិតយុត្តិកា ចំនួន ០១ (មួយ) ច្បាប់

+សលាកប័ត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ ទៅតាមអនុគណនីនិមួយៗ ដែលមានលើអាណត្តិបើកប្រាក់និយ័តកម្ម ចំនួន ០១ (មួយ) ច្បាប់

+តារាងតុល្យភាពរដ្ឋទេយ្យបុរេប្រទាប្រចាំខែ ចំនួន ០១ (មួយ) ច្បាប់

+ប័ណ្ណចំណាយ ដែលចេញដោយរតនាគារខេត្ត-រាជធានី ចំនួន ០១ (មួយ) ច្បាប់ (ច្បាប់ថតចំលង)

+ប័ណ្ណចំណាយរបស់មន្ទីរជំនាញ និងការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុង ចំណាយផ្ទាល់

+ប័ណ្ណចំណាយ ដែលមន្ទីរជំនាញផ្តល់ជូនទៅការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុង ឬ អង្គភាពផ្សេងទៀតក្រោមឱវាទ (ច្បាប់ថតចំលង) ចំនួន ០១ (មួយ) ច្បាប់

+ប័ណ្ណចំណាយ ដែលការិយាល័យស្រុក-ខណ្ឌ-ក្រុង ផ្តល់ជូនទៅអង្គភាពក្រោមឱវាទ (សាលារៀន មណ្ឌលសុខភាព ឬ មន្ទីរពេទ្យ) (ច្បាប់ថតចំលង) ចំនួន ០១ (មួយ) ច្បាប់

+គោលការណ៍ចំណាយ និងវិក័យប័ត្រ របស់មន្ទីរជំនាញខេត្ត-រាជធានី និង ការិយាល័យជំនាញស្រុក-ខណ្ឌ-ក្រុង ចំណាយផ្ទាល់ ចំនួន ០១ (មួយ) ច្បាប់

+របាយការណ៍ចំណាយរដ្ឋទេយ្យបុរេប្រទានរួមចំនួន ០១ (មួយ) ច្បាប់

-ចំពោះប័ណ្ណចំណាយ និងសក្ខីប័ត្ររបស់អង្គភាពផ្សេងៗទៀត ក្រោមឱវាទរបស់ការិយាល័យជំនាញ ស្រុក-ខណ្ឌ-ក្រុង (សាលារៀន មន្ទីរពេទ្យ ឬ មណ្ឌលសុខភាព) ដែលពុំទាន់បានបង្កើតរដ្ឋទេយ្យបុរេប្រទាន និងតែងតាំងរដ្ឋទេយ្យករបុរេប្រទាន គឺត្រូវរក្សាទុកនៅមន្ទីរជំនាញខេត្ត-រាជធានី ហើយរង់ចាំការត្រួតពិនិត្យរបស់អធិការកិច្ចជាក្រោយ ដោយអាជ្ញាធរមានសមត្ថកិច្ច។

-មូលដ្ឋាននៃការផ្ទៀងផ្ទាត់លេខ រវាងរជ្ជទេយ្យករបុរេប្រទានជាមួយនឹងរតនាគារខេត្ត-រាជធានី គឺត្រូវពិនិត្យលើសមតុល្យគណនី ដូចខាងក្រោម៖

-សំរាប់ថវិកាមិនមែនកម្មវិធី : គណនីលេខ ៥៤៣ (នៅរតនាគារខេត្ត-រាជធានី) ជាមួយគណនីលេខ ៥៩.០១ (នៅមន្ទីរខេត្ត-រាជធានី)

-សំរាប់ថវិកាតាមកម្មវិធី : គណនីលេខ ៥៤៤ (នៅរតនាគារខេត្ត-រាជធានី) ជាមួយគណនីលេខ ៥៩.០២ (នៅមន្ទីរខេត្ត-រាជធានី) ។

ចំពោះអង្គភាពស្ថិតក្រោមឱវាទរបស់ក្រសួង-ស្ថាប័ននៅថ្នាក់កណ្តាល ក៏ដូចជាអង្គភាព ឬ ការិយាល័យ ដែលនៅក្រោមឱវាទរបស់មន្ទីរជំនាញខេត្ត-រាជធានី ឬ ការិយាល័យស្រុក-ខណ្ឌ-ក្រុង ដែលបានបង្កើតរជ្ជទេយ្យបុរេប្រទាន ឬ បានតែងតាំងរជ្ជទេយ្យករបុរេប្រទានរួច ត្រូវអនុវត្តកិច្ចបញ្ជិកាទៅតាមខ្លឹមសារនៃសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦។

លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសារាចរណែនាំបន្ថែមនេះ ត្រូវចាត់ទុកជានិរាករណ៍។

ទទួលបានសារាចរណែនាំនេះ សូមគ្រប់ក្រសួង-ស្ថាប័ន នៅថ្នាក់ជាតិ និង មន្ទីរ-អង្គភាព នៅថ្នាក់ក្រោមជាតិ គោរពអនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋានរាជកិច្ច "ដើម្បីផ្សព្វផ្សាយ"
-គ្រប់ក្រសួង-ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន
-គ្រប់ខេត្ត-រាជធានី "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ